# អរិយធម៌ណុក ( Nok Civilization)

នៅអំឡុងដើមពាក់កណ្ដាលនៃទសវត្សរ៍ទី២០ ដែលជាសម័យកាលដែលអ្នកស្រាវជ្រាវបានរកឃើញវត្ថុសិល្បៈជាច្រើនដែលធ្វើអំពីដីដុត (រូបមនុស្ស សត្វជាដើម)និង អំពីលោហធាតុផ្សេងៗ ជាពិសេសឧបករណ៍ដែក នៅក្នុងភូមិបុរាណមួយដែលហៅថា ណុក (Nok) នៅភាគកណ្ដាលនៃប្រទេសនីហ្សេរីយ៉ា[១] ដែលអ្នកស្រាវជ្រាវចាត់ទុកថាជាអរិយធម៌ដែលចាស់ជាងគេក្នុងតំបន់។ អរិយធម៌នេះមានទីតាំងស្ថិតនៅក្បែរនឹងខ្ពង់រាប ចូស (Jos) និងស្ថិតនៅខាង កើតនៃទន្លេនីហ្សេ (Niger) (រូបលេខ១)។

នៅឆ្នាំ ១៩៤៣ អ្នកបុរាណវិទូ ជនជាតិអង់គ្លេសម្នាក់ឈ្មោះ លោក Bernard Fagg បានទៅដល់ទីតាំងភូមិណុកដែលជាភូមិបុរាណមួយ ដោយបានធ្វើការ survey និងកំណាយនៅតំបន់ទីតាំងភូមិនោះ និងប្រទះឃើញវត្ថុសិល្បៈផ្សេងៗផលិត អំពីដីដុតដែលមានទម្រង់ជាមនុស្ស ក្បាលមនុស្ស និងរូបសត្វផ្សេងៗជាដើម។ លើសពីនេះ នៅឆ្នាំ ១៩៦០លោក Fagg បានបន្តធ្វើការកំណាយនៅទីតាំងស្ថានីយមួយផ្សេងទៀត ដែលមានឈ្មោះថា Taruga ដែលស្ថិតនៅខាងត្បូង និងមានចម្ងាយប្រមាណជាង៥៥គីឡូម៉ែត្រពីរាជធានី អាប៊ូចា (Abuja) នៃប្រទេសនីហ្សេរីយ៉ា(រូបលេខ២)។ បន្ទាប់ពីកំណាយនៅទីតាំងស្ថានីយនេះរួច អ្នកស្រាវជ្រាវបានដឹងថាទីតាំងស្ថានីយ៍នេះ ជាទីតាំងដ៏សំខាន់នៅក្នុងអរិយធម៌ណុក ដោយបានរកឃើញនូវភស្តុតាងសំខាន់ជាច្រើនដូចជា វត្ថុសិល្បៈអំពីដីដុត (Terracotta) និងបានរកឃើញនូវចង្ក្រានត្តសម្រាប់ចម្រាញ់ថ្មរ៉ែដែក ឬចង្ក្រានត្តស្ងដែកសម្រាប់ផលិតឧបករណ៍ដែក។[២] ឧបករណ៍ដែកទាំងនោះមានដូចជាពូថៅ ចបជីក ចបកាប់ជាដើម ដែលសម្រាប់ប្រើប្រាស់កសិកម្ម និងជីវភាពប្រចាំថ្ងៃ។[៣]តាមរយៈការសិក្សាលើកាបូន១៤លើវត្ថុសិល្បៈទាំងនោះ

[១] លោក Bernard Fagg ជាអ្នកបានទៅដល់ និងស្រាវជ្រាវពីអរិយធម៌នេះមុនគេ

[២] https://www.researchgate.net/publication/319638198_Early_West_African_Iron_Smelting_The_Legacy_of_Taruga_in_Light_of_Recent_Nok_Research

[៣] https://www.worldhistory.org/Nok_Culture/

អត្ថបទដោយ៖ អេង តុលា

អ្នកស្រាវជ្រាវបានលើកឡើងថាអរិយធម៌នេះ កកើតឡើងនៅរវាងស.វ.ទី៥មុនគ.ស.រហូតដល់ស.វ.ទី២ នៃគ.ស. និងបើតាមការសិក្សាលើចង្រ្កានស្លដែកទាំងនោះ អរិយធម៌នេះអាចមានអាយុកាលចាស់ជាងនេះទៅទៀត ពោលអាចនៅ១០០០ឆ្នាំមុនគ.ស. បើប្រៀបធៀបទៅនឹងវិធីសាស្រ្តចម្រាញ់រ៉ែដែកនៅតំបន់ Hittites ដែលមានអាយុកាលជាង១៥០០ឆ្នាំមុនគ.ស.។ ទោះបីជាយ៉ាងណា វត្ថុសិល្បៈនៃអរិយធម៌នេះបានបង្ហាញថា ណុកជាអរិយធម៌ដែលចាស់ជាងគេនៅក្នុងតំបន់ sub-Saharan[៤] និងបង្ហាញវិសាលភាពទឹកដីនៃអរិយធម៌នេះដោយគ្រប់គ្រង់នៅតំបន់កណ្ដាល និងខាងជើងនៃប្រទេសនីហ្សេរីយ៉ា។[៥]

មនុស្សក្នុងអរិយធម៌នេះមានជំនាញក្នុងការផលិតវត្ថុសិល្បៈ តាមទម្រង់ប្លែក តែមានបច្ចេកទេសខ្ពស់ ដែលភាគច្រើនប្រើប្រាស់បច្ចេកទេសស្លូនដី ទៅជារូបអ្វីមួយ រួចដុតឱ្យឆ្អិន និងមានបច្ចេកទេសក្នុងការស្លដែក ដែលប្រើប្រាស់ចង្រ្កានហៅជាអង់គ្លេសថា *Bloomery*[៦] ដែលជាចង្រ្កានប្រើប្រាស់ច្រើនជាងគេនៅក្នុងតំបន់ទ្វីបអាហ្វ្រិច ( រូបលេខ៣-៥ )។

អ្នកស្រាវជ្រាវពុំដឹងអំពីមូលហេតុច្បាស់លាស់ នៃការដួលរលំអរិយធម៌ណុកនេះទេ ប៉ុន្តែប្រហែលមកពីការប្រែប្រួលអាកាសធាតុក្នុងតំបន់ និងមានការឈ្លានពីអរិយធម៌ដទៃទៀត និងមានកត្តាផ្សេងៗដែលធ្វើឱ្យអរិយធម៌ដែលមានបច្ចេកទេសនេះដួលរលំ។[៧]

សរុបមកអរិយធម៌នេះជាអរិយធម៌ដែលមានបច្ចេកទេសក្នុងការចម្រាញ់រ៉ែ ដែក និងបច្ចេកទេសផលិតវត្ថុសិល្បៈអំពីដីដុត។ តាមរយៈវត្ថុទាំងនោះ បានបង្ហាញថាអរិយធម៌នេះមានឥទ្ធិពលរបស់ខ្លួនរយៈពេលប្រមាណ៣០០ឆ្នាំ ពោលចាប់ឆ្នាំ ៥០០មុនគ.ស.រហូតដល់ឆ្នាំ២០០មុនគ.ស.៕

[៤]https://www.researchgate.net/publication/228965010_New_Studies_on_the_Nok_Culture_of_Central_Nigeria

[៥]FAGG 1959; JEMKUR 1992: 4

[៦]https://www.researchgate.net/figure/The-metallurgy-of-the-bloomery_fig4_275847502

[៧]https://www.nationalgeographic.org/

អត្ថបទដោយ៖ អេង តុលា




រូបលេខ១៖ ផែនទីនៃអរិយធម៌ណុក

(ប្រភព៖ www.worldhistory.com)

KHMER CIVILIZATION




រូបលេខ២៖ ផែនទីនៃស្ថានីយ Taruga

(ប្រភព៖ https://www.researchgate.net/publication/319638198_Early_West_African_Iron_Smelting_The_Legacy_of_Taruga_in_Light_of_Recent_Nok_Research)



រូបលេខ៣៖ រូបចម្លាក់ក្នុងសិល្បៈណុក

ប្រភព៖ https://www.nationalgeographic.org/

អត្ថបទដោយ៖ អេង តុលា



រូបលេខ៤៖ រូបចម្លាក់ក្នុងសិល្បៈណុក

ប្រភព៖ www.worldhistory.com



រូបលេខ៥៖ ចង្ក្រាន្តស្ងដែក

ប្រភព៖ www.worldhistory.com

អត្ថបទដោយ៖ អេង តុលា

# ឯកសារយោង

https://www.researchgate.net/publication/319638198_Early_West_African_Iron_Smelting_The_Legacy_of_Taruga_in_Light_of_Recent_Nok_Research

https://www.worldhistory.org/Nok_Culture/

https://www.researchgate.net/publication/228965010_New_Studies_on_the_Nok_Culture_of_Central_Nigeria

https://www.researchgate.net/figure/The-metallurgy-of-the-bloomery_fig4_275847502

https://www.nationalgeographic.org/

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា